ទីក្រុងឡុងប៊ិច
ការិយាល័យព័ត៌មានសាធារណៈ
៤១១ W. Ocean Blvd,
ឡុងប៊ិច, កាលីហ្វ័រញ៉ា ៩០៨០២

# សេចក្តីប្រកាសព័ត៌មាន

4/18/2020

សម្រាប់សេចក្តីប្រកាសបន្ទាន់ សេចក្តីប្រកាសព័ត៌មាន #041820

**ប្រធានបទ៖ ទីក្រុងឡុងប៊ិចបង្ហាញគេហទំព័រកូវីដ-១៩ដែលទើបរចនាថ្មី**
ផ្ទាំងគ្រប់គ្រងទិន្នន័យថ្មីអំពីកូវីដ-១៩ត្រូវបានបង្ហាញ

**ទំនាក់ទំនង៖** មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច
៥៦២.៥៧០.NEWS (សម្រាប់ទទួលសំណួរពីអ្នកសារព័ត៌មានតែប៉ុណ្ណោះ)
jic@longbeach.gov (សម្រាប់ទទួលសំណួរពីអ្នកសារព័ត៌មានតែប៉ុណ្ណោះ)
ប្រជាពលរដ្ឋ៖សូមទូរស័ព្ទទៅលេខ ៥៦២.៥៧០.INFO (៤៦៣៦)

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា - មន្ទីរសុខាភិបាលនិងសេវាប្រជាជននៃទីក្រុងឡុងប៊ិចបានកែលម្អគេហទំព័រកូវីដ-១៩(Covid-19)ជាថ្មីដោយការបង្កើនមុខងារនិងលក្ខណៈច្នៃប្រឌិតរួមទាំងផ្ទាំងគ្រប់គ្រងទិន្នន័យដើម្បីផ្តល់ភាពងាយស្រួល បង្កើនតម្លាភាពនៃទិន្នន័យ និងធ្វើអោយប្រសើរឡើងនូវបទពិសោធន៍ទូទៅនៃអ្នកប្រើប្រាស់។

លោកអភិបាលក្រុង Robert Garcia មានប្រសាសន៍ថា "យើងចាំបាច់ត្រូវមានតម្លាភាពនិងបញ្ចេញទិន្នន័យនិងព័ត៌មានដល់ប្រជាជនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ផ្ទាំងគ្រប់គ្រងទិន្នន័យនិងគេហទំព័រថ្មីរបស់យើងផ្តល់ព័ត៌មានជាសាធារណៈតាមពេលវេលាជាក់ស្តែងអំពីវិបត្តិជម្ងឺកូវីដ-១៩។"

## ផ្ទាំងគ្រប់គ្រងទិន្នន័យ

ឥឡូវនេះគេហទំព័រមានផ្ទាំងគ្រប់គ្រងទិន្នន័យអន្តរកម្មដែលផ្តល់ជូនជាសាធារណៈនូវព័ត៌មានទាក់ទងនឹងករណីវិជ្ជមាន ចំនួនបុគ្គលដែលត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ទិន្នន័យប្រជាសាស្ត្រ និងទិន្នន័យជាច្រើនទៀត។ ផ្ទាំងគ្រប់គ្រងទិន្នន័យនេះជួយប្រជាជនឱ្យមើលឃើញព័ត៌មានលម្អិតច្រើនជាងការចេញផ្សាយពីមុនហើយឥឡូវនេះផ្តល់នូវការប្រៀបធៀបរវាងទីក្រុងនានាក្នុងតំបន់ផ្សេងៗ។ មាតិកា

ផ្សេងៗនៃផ្ទាំងគ្រប់គ្រងត្រូវបានធ្វើឱ្យមានបច្ចុប្បន្នភាពនៅពេលដែលមានព័ត៌មានថ្មីចូលមក។ ដូច្នេះសាធារណជននឹងទទួលបានព័ត៌មានថ្មីៗបំផុត។

**ការរចនាកាន់តែប្រសើរឡើង**

ដោយមានប្លង់ទំនើបនិងមិនស្មុគស្មាញគេហទំព័រដែលត្រូវបានរចនាជាថ្មីនេះបង្ហាញនូវព័ត៌មានដែលមានទីតាំងជាយុទ្ធសាស្ត្រក្នុងចំណុចប្រទាក់វិចារណញាណដែលមានអក្សរនិងក្រាហ្វិចផ្អែកលើរូបភាព។ គេហទំព័រនេះត្រូវបានរចនានិងរៀបចំឱ្យប្រសើរឡើងដោយគិតពីភាពងាយស្រួលរបស់អ្នកប្រើប្រាស់។ ព័ត៌មានត្រូវបានប្រមូលជាពិសេសសម្រាប់សាធារណជនទូទៅ អ្នកជំនួញ អ្នកផ្តល់សេវាព្យាបាលនិងអ្នកដែលបម្រើដល់ប្រជាជនដែលមានហានិភ័យខ្ពស់។ ដូច្នេះឥឡូវនេះអ្នកប្រើប្រាស់គេហទំព័រអាចរកឃើញព័ត៌មានដែលពួកគាត់ត្រូវការយ៉ាងឆាប់រហ័សនិងងាយស្រួល។

**ព័ត៌មានទាន់ហេតុការណ៍**

មាតិកាដែលត្រូវបានស្វែងរកជាញឹកញាប់ដូចជារោគសញ្ញានិងវិធីការពារពីជម្ងឺកូវីដ-១៩និងព័ត៌មានអំពីបទបញ្ជារបស់មន្ត្រីសុខាភិបាលនៃទីក្រុងឡុងប៊ិចមានលក្ខណៈលេចធ្លោរួមជាមួយចំនួនករណីនិងព័ត៌មានថ្មីៗ។ ព័ត៌មានអំពីការធ្វើតេស្តនិងការណាត់ជួបក៏ត្រូវបានបង្ហាញផងដែរសម្រាប់ទីតាំងធ្វើតេស្តចំនួន ៥ នៅឡុងប៊ិច។ ទីក្រុងនៅតែបន្តស្វែងរកទីតាំងធ្វើតេស្តបន្ថែមទៀតហើយថ្មីៗនេះបានបន្ថែមទីតាំងធ្វើតេស្តថ្មីចំនួន ២ កន្លែងនៅឯសាលារៀន Cabrillo និងសាលារៀន Jordan។

គេហទំព័រថ្មីនេះក៏ងាយស្រួលប្រើនៅលើទូរស័ព្ទដៃផងដែរ។ ទំព័រ "ជំនួយនិងអ្នកស្ម័គ្រចិត្ត" ត្រូវបានប្តូរទិន្នន័យថ្មីដើម្បីសម្រួលដល់ការចុះឈ្មោះសម្រាប់អ្នកស្ម័គ្រចិត្តផ្នែកវេជ្ជសាស្ត្រនិងអ្នកស្ម័គ្រចិត្តដែលមិនមែនជាពេទ្យក៏ដូចជាគាំទ្រដល់សាធារណជនក្នុងការចុះឈ្មោះបរិច្ចាគទំនិញ សេវាកម្ម ឬថវិកា។ អ្នកប្រើប្រាស់គេហទំព័រក៏អាចកំណត់ពេលណាត់ជួបសម្រាប់ការធ្វើតេស្តតាមឡានដោយឥតគិតថ្លៃនៅទីតាំងផ្សេងៗក្នុងទីក្រុង។

បន្ថែមពីលើការផ្តល់ធនធានផ្សេងៗតាមអ៊ិនធរណេតទីក្រុងនៅតែបន្តមានបុគ្គលិកប្រចាំដើម្បី

ទីក្រុងឡុងប៊ិច
ការិយាល័យព័ត៌មានសាធារណៈ
៤១១ W. Ocean Blvd,
ឡុងប៊ិច, កាលីហ្វ័រញ៉ា ៩០៨០២

លើកទូរស័ព្ទហើយឆ្លើយសំណួរទាក់ទងនឹងការរាលដាលនៃជម្ងឺកូវីដ-១៩ (562.570.4636) និងលើកទូរស័ព្ទហើយឆ្លើយសំណួរពីបណ្ដាញទូរស័ព្ទបន្ទាន់សម្រាប់អាជីវកម្មនិងនិយោជិករបស់ពួកគេ (562.570.4249)។

សម្រាប់ព័ត៌មានថ្មីៗអំពីកូវីដ-១៩នឹងព័ត៌មានលំអិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រដែលរចនាថ្មី៖ longbeach.gov/COVID19 និងតាមដាន @LongBeachCity នៅលើហ្វេសប៊ុក ធ្វីតធ័រ និង Instagram ។

សម្រាប់ព័ត៌មានបន្ថែម រូបភាព វីដេអូ និងសេចក្ដីប្រកាសអំពីអ្វីដែលកំពុងកើតឡើងនៅឡុងប៊ិចសូមតាមដានទីក្រុងឡុងប៊ិចនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

###